ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខៈ ០០៧/១៧ រ.ប.ក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០១៧

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៦
## និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៧

(ថ្ងៃទី០១ ខែធ្នូ ២០១៥ ដល់ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦)

ក្នុងឆ្នាំ២០១៦នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួម និងគាំទ្រយ៉ាងសកម្មពីស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ កាកបាទក្រហមកម្ពុជា វិស័យសាសនា វិស័យឯកជន សប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា បានអនុវត្តផែនការយុទ្ធសាស្ត្រពហុវិស័យនៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន សំដៅចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភា និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ។ តាមរយៈការអនុវត្តផែនការខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍គ្រឿងញៀនជាតិ និងអន្តរជាតិ ព្រមទាំងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងឆ្នាំ២០១៦នេះ ក៏ដូចជាបណ្តាឆ្នាំមុនៗដែរ ពិភពលោកទាំងមូលនៅតែបន្តទទួលរងនូវឥទ្ធិពលនៃការផលិត ការចរាចរគ្រឿងញៀនពីតំបន់សំខាន់ៗដូចជា តំបន់អាមេរិកខាងត្បូង តំបន់អាហ្វ្រិក តំបន់អឌ្ឍចន្ទមាស និងតំបន់ត្រីកោណមាស ។ ជាមួយនឹងស្ថានភាពនេះ ពិភពលោកក៏បាននិងកំពុងប្រឈមជាមួយនឹងការប្រើបំពានសារធាតុញៀនថ្មី ដែលពុំទាន់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ នៅឡើយ ។

ដោយឡែក កម្ពុជាយើងមិនមែនជាប្រទេសផលិតគ្រឿងញៀនទេ ប៉ុន្តែកម្ពុជាបាននិងកំពុងទទួលរងនូវផលប៉ះពាល់ពីការចរាចរគ្រឿងញៀនឆ្លងកាត់ពីតំបន់នានាក្នុងពិភពលោក ពិសេសតំបន់ត្រីកោណមាសចូលតាមច្រកភាគខាងជើង និងឦសានប្រទេស ។ ដោយសារឥទ្ធិពលនេះធ្វើឱ្យការចរាចរ ជួញដូរគ្រឿងញៀនតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស តាមបញ្ញើប្រៃសណីយ៍ តាមគ្រប់រូបភាព និងការប្រើប្រាស់គ្រឿងញៀននៅកម្ពុជា បានរីករាលដាលគួរឱ្យព្រួយបារម្ភ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖**

ឆ្នាំ២០១៦នេះ ក្រសួង-ស្ថាប័ន, ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងខេត្តមួយចំនួន, វិទ្យាល័យក្នុងរាជធានីភ្នំពេញ និងខេត្តមួយចំនួន, មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកដែលមានផ្តល់សេវាព្យាបាលដោយផ្អែកលើសហគមន៍ ដូចមានឈ្មោះក្នុងទំព័រទី០១-០២ នៃតារាងឧបសម្ព័ន្ធ បានចូលរួមផ្តល់កិច្ចសម្ភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ-ទូរទស្សន៍រដ្ឋ និងឯកជន) ពាក់ព័ន្ធនឹងការងារបង្ការ ទប់ស្កាត់ការចរាចរ ជួញដូរ រក្សាទុក ការប្រើប្រាស់ និងការព្យាបាលអ្នកញៀនគ្រឿងញៀន ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀនដល់ប្រជាពលរដ្ឋ ។

**១.២ កម្មវិធីអប់រំផ្សព្វផ្សាយតាមសហគមន៍ ៖**

អគ្គលេខាធិការដ្ឋាន និងក្រសួង-ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ. ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ២១ បានចូលរួមបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន តាមរយៈសកម្មភាពនិងវេទិកានានា រួមទាំងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការដុតបំផ្លាញវត្ថុតាងគ្រឿងញៀន ដែលមានមហាជនទៅទទួលសារអប់រំប្រមាណ **១៣.៧៧៤.៧៣៩** នាក់ (ដូចមានក្នុងទំព័រទី៦នៃតារាងឧបសម្ព័ន្ធ) លើ ១១.១៥៦.៥៩៦ នាក់ នៃឆ្នាំ២០១៥ កើនឡើង ២.៥០៤.០៨៤ នាក់ ស្មើនឹង ២៣,៤៦% និងមានក្រុមជនបង្គោល **២.៨៣១** នាក់ ដែលបានធ្វើការបណ្តុះបណ្តាលសមត្ថភាពបន្ថែមសម្រាប់ជួយដល់ការងារនេះ ។ ដោយឡែក តាមរយៈគេហទំព័រ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានការចូលអានចំនួន **៤៣៦.៦៩៨** ដង ។ ជាមួយនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដំឡើងប៉ាណូរូបភាពអប់រំ បង្ការ ទប់ស្កាត់បញ្ហាគ្រឿងញៀនចំនួន ០៩ នៅតាមច្រកគោលដៅរបស់ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ហើយក៏បានដំឡើងប៉ាណូផ្សព្វផ្សាយពីសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្នុងរាជធានីភ្នំពេញចំនួន ២១ កន្លែង ។

ដោយឡែកវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ជាអាទិ៍ ធនាគារ អេ.ស៊ី.លី.ដា. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត LOLC អង្គការខាន់ណា និងសមាគមយុវជនខ្មែរ បានគាំទ្រជា ខិត្តប័ណ្ណ ផ្ទាំងរូបភាព សម្រាប់ការងារផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនប្រមាណ ១៥១.០០០ សន្លឹក ។

### ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

**២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានទៅចូលរួម និងរៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សានានា ជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ ទាំងក្នុង និងក្រៅប្រទេសសរុបបានចំនួន ២២ លើក ដែលមានមន្ត្រីចូលរួមសរុប ៣៩៥ នាក់ ក្នុងនោះមន្ត្រីអគ្គលេខាធិការដ្ឋាន **៥៥** នាក់ ដែលប្រធានបទនៃកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សាទាំងនោះ មាននៅទំព័រទី៧-៨ នៃតារាងឧបសម្ព័ន្ធ ។

**២.២. កម្មវិធីបំប៉នសមត្ថភាពលើការព្យាបាល និងស្តារនីតិសម្បទា ៖**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានទៅចូលរួម និងរៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សានានា ជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ទាំងនៅក្នុង និងក្រៅប្រទេសសរុបបានចំនួន ២៨ លើក មានមន្ត្រីចូលរួមសរុប ៤៤៨ នាក់ ក្នុងនោះមន្ត្រីអគ្គលេខាធិការដ្ឋាន **៦៩** នាក់ ។ ប្រធានបទនៃកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាទាំងនោះ មាននៅទំព័រទី៩-១០ នៃតារាងឧបសម្ព័ន្ធ ។

ជាមួយនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏បានផ្តល់នូវម៉ាស៊ីនដេរ ម៉ាស៊ីនផុង ដល់មណ្ឌលឱកាសខ្ញុំ សម្រាប់បណ្តុះបណ្តាលដល់អ្នកផ្តាច់សារធាតុញៀន មុននឹងសមាហរណកម្មទៅកាន់សហគមន៍វិញ ។

**២.៣. ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៖**

ឆ្នាំនេះ អ្នកប្រើគ្រឿងញៀននៅទូទាំងប្រទេសមាន **២០.៦២១** នាក់ លើ ១៦.៥៧៥ នាក់ នៃឆ្នាំ២០១៥ កើនឡើង ៤.០៤៦ នាក់ ស្មើនឹង ២៤,៤១ % ក្នុងនោះ ៖

- អ្នកប្រើគ្រឿងញៀន ដែលមិនបានទៅទទួលសេវាព្យាបាល មាន **៩.០២០** នាក់ ស្មើនឹង ៤៥,១២ % នៃចំនួនអ្នកញៀនសរុប (អ្នកប្រើគ្រឿងញៀននៅតាមភូមិ ឃុំ) មាននៅទំព័រទី១១ នៃតារាងឧបសម្ព័ន្ធ

- អ្នកប្រើគ្រឿងញៀន ដែលបានទៅទទួលសេវាព្យាបាល មាន **១១.៦០១** នាក់ ស្មើនឹង ៥៦,២៥ % នៃចំនួនអ្នកញៀនសរុប ។ ការថែទាំ ព្យាបាលអ្នកញៀនគ្រឿងញៀន ត្រូវបានអនុវត្តតាម ២ ប្រព័ន្ធគឺ ៖

**- ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍តាមមូលដ្ឋានសុខាភិបាល ៖**

អ្នកញៀនគ្រឿងញៀនដែលស្ម័គ្រចិត្តទៅទទួលសេវាព្យាបាលដោយផ្អែកលើសហគមន៍ តាមមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ចំនួន ១៧៧ មូលដ្ឋាន) សរុបមាន **៤.៣០០** នាក់ ដូចមាននៅក្នុងទំព័រទី១២-២២ នៃតារាងឧបសម្ព័ន្ធ ។

**- ការព្យាបាលតាមមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទា របស់រដ្ឋ និង ឯកជន ៖**

បានផ្តល់សេវាថែទាំ ព្យាបាលអ្នកញៀនគ្រឿងញៀនចំនួន **៧.៣០១** នាក់ មាននៅក្នុងទំព័រទី២៣-៣១ នៃតារាងឧបសម្ព័ន្ធ ។ ក្នុងនោះ ៖

- ព្យាបាលនៅក្នុងមណ្ឌលរបស់រដ្ឋ មាន ៥.០៥៤ នាក់
- ព្យាបាលនៅក្នុងមណ្ឌលរបស់ឯកជន មាន ២.២៥៧ នាក់

ក្នុងចំនួន ៧.៣០១ នាក់ ខាងលើ យើងបានរកឃើញ ៖

**អាយុអ្នកប្រើគ្រឿងញៀន**

| ៩ ឆ្នាំចុះ | ១០-១៧ ឆ្នាំ | ១៨-២៥ ឆ្នាំ | ២៦-៣៥ ឆ្នាំ | ៣៦-៤៥ ឆ្នាំ | ៤៦ ឆ្នាំឡើង |
|---|---|---|---|---|---|
| | ៥,២០ % | ៤៣,៩៣ % | ៤១,០៧ % | ៧,៨៦ % | ១,៩១ % |

**ប្រភេទគ្រឿងញៀនប្រើប្រាស់**

| WY | ICE | អ៊ិចស្តាស៊ី | ហេរ៉ូអ៊ីន | កេតាមីន | កញ្ឆា | ការហិត | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១៧,៩១ % | ៧១,០៤ % | ១,០៥ % | ០,៧៥ % | ០,៩១ % | ១,១៧ % | ១,៨០ % | ៥,៣១ % |

**មុខរបរអ្នកប្រើប្រាស់**

| មន្ត្រីរាជការ | សិស្ស និស្សិត | កន្លែងសប្បាយ | កម្មករ ពលករ | អ្នកជំនួញ | គ្មានរបរពិតប្រាកដ | ជនអនាថា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ២,៩៩ % | ២៨,៦១ % | ០,៤១ % | ២១,២១ % | ៥,០៤ % | ២៦,៨៨ % | ៤,២៤ % | ១០,៥៨ % |

- **បានធ្វើសមាហរណកម្មចេញពីមណ្ឌលបណ្តោះអាសន្ន របស់រដ្ឋ និង ឯកជន ចំនួន ២.៥១៥** នាក់
- **កំពុងស្នាក់នៅព្យាបាលបន្តក្នុងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ និង ឯកជន** (យកចំនួនស្នាក់នៅជាក់ស្តែងក្នុងត្រីមាសទី៤) សរុប **២.៥៩៩** នាក់

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ ៖

- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបើកវគ្គបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទ រួមទាំងមន្ត្រីកងទ័ព នៅក្នុងប្រទេសសរុបបានចំនួន **៣.៩៣៨** នាក់ ក្នុងនោះ មន្ទីរប្រឆាំងគ្រឿងញៀនបណ្តុះបណ្តាលបានចំនួន ១.១៤២ នាក់ និងបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា នៅក្រៅប្រទេស សរុបបានចំនួន **១៨០** នាក់ ក្នុងនោះ មន្ត្រីអគ្គលេខាធិការដ្ឋាន ៥៤ នាក់ ។

- សរុបទាំងក្នុង និងក្រៅប្រទេសមានចំនួន **៤.១១៨** នាក់ ក្នុងនោះ មន្ត្រីអគ្គលេខាធិការដ្ឋាន ១៦៤ នាក់ ។ (ទំព័រទី៣៩-៤២ នៃតារាងឧបសម្ព័ន្ធ) ។

៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន ៖

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤.២៤៦** ករណី (រួមទាំងករណីប្រើប្រាស់) លើ ៣.០៦១ ករណី (រួមទាំងករណីប្រើប្រាស់) នៃឆ្នាំ២០១៥ កើនឡើង ១.១៨៥ ករណី ស្មើនឹង ៣៨,៧១ %

- **ជនសង្ស័យ**ឃាត់ខ្លួន **៩.៩៣៣** នាក់ / ស្រី ៩៦៤ នាក់ (រួមទាំងអ្នកប្រើប្រាស់) លើ ៧.០០៨ នាក់ (រួមទាំងអ្នកប្រើប្រាស់) នៃឆ្នាំ២០១៥ កើនឡើង ២.៩២៥ នាក់ ស្មើនឹង ៤១,៧៣ % (មាននៅទំព័រទី៤៣-៤៤ នៃតារាងឧបសម្ព័ន្ធ) ។

ក្នុងចំនួនបទល្មើសគ្រឿងញៀនទាំង **៤.២៤៦** ករណី ខាងលើគឺ ៖

- បទល្មើសបង្ក្រាបដោយ**សមត្ថកិច្ចនគរបាល** មាន **៣.២៧៥** ករណី ឃាត់ខ្លួនជនសង្ស័យ **៧.១៥៩** នាក់ (ស្រី ៥៣៩ នាក់) រួមទាំងអ្នកប្រើប្រាស់ ។ ក្នុងនោះមាន ០៧ ករណី ត្រូវបានមន្ទីរប្រឆាំងគ្រឿងញៀនសហការជាមួយកម្លាំងចម្រុះ (រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, អគ្គនាយកដ្ឋានអន្តោប្រវេសន៍, អគ្គនាយកដ្ឋានគយនិងរដ្ឋាករ, អគ្គនាយកដ្ឋានកាំកុងត្រូល) បង្ក្រាបនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តសៀមរាប ។

ជាមួយនេះដែរ ក៏មានមួយករណីទៀតដែលគណៈកម្មការជាតិត្រួតពិនិត្យគ្រឿងញៀនចិន បានអនុវត្តវិធានការប្រគល់ដោយមានការឃ្លាំមើល នៅឯទីក្រុងសៀងហៃ ឈានទៅដល់ការចាប់យកជាសម្ងាត់នូវ កូកាអ៊ីន ចំនួន ១ តោន ១០២ គីឡូក្រាម ដែលឧក្រិដ្ឋជនបានបង្កប់នៅក្នុងកុងតឺន័របង្កកត្រី ចំនួន ៣ រួចបានផ្តល់អត្តសញ្ញាណនាវាទាំងនោះមក អ.ជ.ប.គ.ញ. ជាមុន ទើបបណ្តោយឱ្យវានាធ្វើដំណើរបន្តមកដល់គោលដៅកំពង់ផែសមុទ្រក្រុងព្រះសីហនុ ។ អ.ជ.ប.គ.ញ. បានបញ្ជូនព័ត៌មាននេះជាបន្ទាន់ទៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីបើកកិច្ចប្រតិបត្តិការបង្ក្រាប ដោយបានឃាត់ខ្លួនឧក្រិដ្ឋជនវៀតណាម ១ នាក់ និងកំពុងបន្តកិច្ចសហការស្វែងរកចាប់មេខ្លោងនិងបក្សពួកដែលនៅសេសសល់ ។

- បទល្មើសបង្ក្រាបដោយ**សមត្ថកិច្ចកងរាជអាវុធហត្ថ** មាន **៩៧១** ករណី ឃាត់ខ្លួនជនសង្ស័យ **២.៧៧៤** នាក់ (ស្រី ១៥២ នាក់) រួមទាំងអ្នកប្រើប្រាស់ ។

ក្នុងចំណោមជនសង្ស័យដែលបានឃាត់ខ្លួនទាំង **៩.៩៣៣** នាក់ មាន ២១ សញ្ជាតិ ដូចមានរាយនៅក្នុងទំព័រទី ៤៥-៤៦ នៃតារាងឧបសម្ព័ន្ធ ។

- **គ្រឿងញៀន និងសារធាតុផ្សំ**ចាប់យកសរុប **១៧៩** គ.ក្រ **៨៥៨** ក្រាម **៨៥** (គ្រឿងញៀនសំយោគមាន ១៣៣ គ.ក្រ ៤៩៧ ក្រាម ៦៥, កញ្ឆា ៣៦ គ.ក្រ ៨៦១ ក្រាម ២០, ប្រេងម្រេះព្រៅ ៩៥ គ.ក្រ) ។ ក្នុងនោះមាន ៥៥ ករណីគ្រឿងញៀនសំយោគធំៗ ដែលបានចាប់យកគ្រឿងញៀនប្រមាណ **៩៥** គ.ក្រ **១៩៥** ក្រាម **៦៣** ស្មើនឹង ៧១,៣០ % នៃចំនួនគ្រឿងញៀនសំយោគសរុប ដូចមានរាយក្នុងតារាងខាងក្រោម ៖

| ប្រភេទគ្រឿងញៀន | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ | កើនឡើង | ថយចុះ |
|---|---|---|---|---|
| មេតំហ្វេតាមីន ICE | ៦៦ គ.ក្រ ៣៣២ ក្រាម ០៧ | ៧២ គ.ក្រ ៨៥៨ ក្រាម ៣៦ | | ៨,៩៥% |
| មេតំហ្វេតាមីនគ្រាប់ WY | ៤៤ គ.ក្រ ១៦២ ក្រាម ៤៦ | ២៦ គ.ក្រ ៥៧៦ ក្រាម ៦២ | ៦៦,១៧% | |
| អ៊ិចស្តាស៊ី | ១ គ.ក្រ ៦៥២ ក្រាម ៦០ | ២១ ក្រាម ២៦ | កើនឡើងខ្លាំង | |
| ហេរ៉ូអ៊ីន | ៦ គ.ក្រ ២៧១ ក្រាម ៩៥ | ២ គ.ក្រ ៤៦៤ ក្រាម ៧៩ | ១៥៤,៤៦% | |
| កូកាអ៊ីន | ១៤ គ.ក្រ ០០៤ ក្រាម ៨៦ | ៥ គ.ក្រ ២៥០ ក្រាម | ១៦៦,៧៥% | |
| កេតាមីន | ១ គ.ក្រ ០៧៣ ក្រាម ៧១ | ១០៦,០៦ ក្រាម | កើនឡើងខ្លាំង | |
| កញ្ឆាក្រៀម | ៣៦ គ.ក្រ ៨៦១ ក្រាម ៦៩ | ១.៥១១ គ.ក្រ ៤២០ ក្រាម ៧១ | | ថយចុះខ្លាំង |
| ដើមកញ្ឆា | ៧៩.៥៧៣ ដើម | ១២.៤១៥ ដើម | | |
| ប្រេងម្រះព្រៅភ្នំ (Kg) | ៩៥ គ.ក្រ | គ្មាន | | |

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន ៖ រថយន្ត ៦៧ គ្រឿង, ម៉ូតូ ១.៨២៨ គ្រឿង, ប្រាក់កម្ពុជា ៩៨.៤៣០.៤០០ រៀល, ប្រាក់ថៃ ៥៩.០០០ បាត, ប្រាក់វៀតណាម ១៦៥.៣៦០.០០០ ដុង, ប្រាក់អាមេរិក ៣២.៩៦៩ ដុល្លារ, ប្រាក់ឡាវ ១៥.០០០ គីប, ប្រាក់ចិន ២០០ យ័ន និងប្រាក់កូរ៉េ ១.០០០ វ៉ុន ។

- **ជនសង្ស័យ** ចាប់តាមដីកា មាន ២៤០ ដីកា ឃាត់ខ្លួនជនសង្ស័យ ២២៩ នាក់ (ស្រី ២២ នាក់) ។

**៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ៖**

មន្ទីរពិសោធន៍គ្រឿងញៀននៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀនបាន **២.៥៥២** សំណាក = **២.២១៥** ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន ២.៤៨៤ សំណាក = ២.១៧៩ ករណី គឺ ៖**
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២.១៩៩ សំណាក (៨៦,១៦ %)
  - មេតំហ្វេតាមីនគ្រាប់ (WY) ២២០ សំណាក (៨,៦២ %) -កញ្ឆា ១០ សំណាក (០,៣៩ %)
  - កេតាមីន ១៤ សំណាក (០,៥៤ %) -កូកាអ៊ីន ០២ សំណាក (០,០៧%)
  - ហេរ៉ូអ៊ីន ២៣ សំណាក (០,៩០ %) -MDMA ១២ សំណាក (០,៤៧ %)
  - នីមេតាហ្សេប៉ាម ០២ សំណាក (០,០៧ %) -ឌីយ៉ាហ្សេប៉ាម ០១ សំណាក (០,០៣ %)
  - ប្រ៊ោម៉ាហ្សេប៉ាម ០១ សំណាក (០,០៣ %)
- **សំណាកអវិជ្ជមានសារធាតុញៀន ៦៨ សំណាក = ៣៦ ករណី**

ក្រៅពីការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន មន្ទីរពិសោធន៍របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានផ្តល់ដល់ស្ថាប័នអនុវត្តន៍ច្បាប់នូវ ៖

- ស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន សរុបចំនួន ១.៧៥០ ស្រោម
- តេស្តរកសារធាតុញៀនក្នុងទឹកនោម ២៥.៩៦០ តេស្ត -ម៉ាគ្វីតេស្ត ២១៥ តេស្ត និង ១០ ដប
- ស៊ីម៉ុនតេស្ត ៥០ តេស្ត និង ២ ដប -កេតាមីនតេស្ត ៥៥ តេស្ត -កូកាអ៊ីន ២០ តេស្ត
- ចានធ្វើតេស្តបឋម ១ បន្ទះ -ជញ្ជីងថ្លឹងវត្ថុតាងគ្រឿងញៀន ១០

**៣.៤. អំពីចំណាត់ការរបស់អយ្យការ** ៖ សំណុំរឿងសរុប ៦២៨ រឿង ចាត់ការរួច ៥៣២ រឿង ក្នុងនោះ

បញ្ជូនរឿងទៅស៊ើបសួរ ៥០៨ រឿង / បញ្ជូនទៅជម្រះផ្ទាល់ ២០ រឿង / តម្កល់ទុកឥតចាត់ការ ០៤ រឿង និង កំពុងចាត់ការ ៩៦ រឿង ។

➢ **អំពីចំណាត់ការរបស់ចៅក្រមស៊ើបសួរ ៖** សំណុំរឿងសរុប ៤៨៩ រឿង (ចាត់ការរួច ១៩៩ រឿង)

ក្នុងនោះ បញ្ជូនទៅជំនុំជម្រះ ១៨៩ រឿង, លើកលែងចោទប្រកាន់ ១០ រឿង និង កំពុងចាត់ការ ២៩០ រឿង (ជនត្រូវចោទសរុប ៩៥៦ នាក់)

➢ **អំពីចំណាត់ការរបស់ចៅក្រមជំនុំជម្រះ ៖** សំណុំរឿងសរុប ៣០១ រឿង ចាត់ការរួច ២០៤ រឿង ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

សារធាតុគីមី ពាក់ព័ន្ធនឹងតារាង**ទី៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលនាំចូលក្នុងឆ្នាំ២០១៦ មានចំនួន **៩.៤៣០.៧៩៦** គ.ក្រ និង **១៤៣** លីត្រ ក្នុងនោះ ៖

• មានអាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដារប្រើប្រាស់សារធាតុគីមី ផ្តល់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម **៧.២១៨.៤០៥** គ.ក្រ និង **១៤៣** លីត្រ

• មានអាជ្ញាប័ណ្ណផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា **២.២១៨.៣៩១** គ.ក្រ

• មានអាជ្ញាប័ណ្ណផ្តល់ដោយក្រសួងសុខាភិបាល ក្នុងទម្រង់ជាវត្ថុធាតុដើម មាន **២០០** គ.ក្រ, ក្នុងទម្រង់ជាឱសថ **៣** គ.ក្រ **៣០២** ក្រាម និង **៥៦០** មិល្លីក្រាម ។

សារធាតុញៀន ពាក់ព័ន្ធនឹងតារាង**ទី២** និង **ទី៣** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលនាំចូលដោយក្រសួងសុខាភិបាល ក្នុងទម្រង់ជាវត្ថុធាតុដើម និងក្នុងទម្រង់ជាឱសថមានផ្ទុកសារធាតុញៀន ។

ក្រៅពីការគ្រប់គ្រងទិន្នន័យសារធាតុគីមីផ្សំ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៖

- បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប ចូលជាសមាជិកនៃគណៈកម្មការអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- បានប្រជុំផ្សព្វផ្សាយអំពីការទប់ស្កាត់ ការបង្វែរសារធាតុគីមីផ្សំទៅផលិតសារធាតុញៀន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

បានបន្តសម្របសម្រួល និងពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ត្រីភាគី ជាមួយប្រទេសថៃ ឡាវ និងវៀតណាម តាមរយៈការបញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ទៅចូលរួមក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា បាន ៣៦ លើក មានមន្ត្រីចូលរួម **១២៧** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **២៦** នាក់) ។ ខ្លឹមសារនៃកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាទាំងនោះ មាននៅទំព័រទី៧០ នៃតារាងឧបសម្ព័ន្ធ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

ជារួម អ.ជ.ប.គ.ញ. បានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈកិច្ចប្រជុំប្រចាំឆ្នាំ ការពង្រឹងយន្តការក្នុងការអនុវត្តផែនការសកម្មភាពនានា ជាមួយបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ ប្រទេសក្នុងតំបន់-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍បាន ២៥ លើក / មន្ត្រីចូលរួម **៦០** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ៣២ នាក់) ។ ខ្លឹមសារនៃកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា និងកិច្ចសហប្រតិបត្តិការលើគម្រោងផ្សេងៗ ។

ដោយឡែក គណៈកម្មការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC) បានស្នើសុំការសម្របសម្រួលពី អ.ជ.ប.គ.ញ. ដើម្បីសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការអនុវត្តបន្តនូវវិធានការប្រគល់ដោយមានការឃ្លាំមើល បន្ទាប់ពីការចាប់ កូកាអ៊ីន ចំនួន ១ តោន ១០២ គ.ក្រ នៅទីក្រុងសៀងហៃ ដោយបានចេញនិវេទន៍ក្រហមតាមរកចាប់ខ្លួនក្រុមមេខ្លោង និងបក្សពួកដែលនៅសេសសល់ ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានយកចិត្តទុកដាក់ពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ តាមរយៈការចុះទៅពង្រឹងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតាមរាជធានី-ខេត្ត និងទិសដៅការងារទាំង ០៨ ចំណុច ដែលគាំទ្រដោយសម្តេចអគ្គមហាសេនាបតីតេជោ ក៏ដូចជាទិសដៅការងារដែលបានដាក់ចេញនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៥-២០១៦ របស់ អ.ជ.ប.គ.ញ. ។

លទ្ធផលជារួមគ្រប់រាជធានី ខេត្ត បានរៀបចំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ក្រុង ស្រុក របស់ខ្លួនរួចរាល់ជាស្ថាពរ ។ ដោយឡែក ខេត្តមួយចំនួនទៀត បាននិងកំពុងជំរុញការរៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់សង្កាត់ ឃុំ ។

- រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានចេញប្រកាសរួមលេខ ៥៧៦ សហវ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែង ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

- បានចេញប្រកាសរួមលេខ ៥៧៧ សហវ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូល ដែលបានមកពីការបង្ក្រាបបទល្មើសគ្រឿងញៀន

- បានចេញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

- បានបង្កើតក្រុមការងារកែសម្រួលមាត្រា៨៧ និងមាត្រាមួយចំនួន នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

- បានសហការជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ចុះពង្រឹងកិច្ចការគ្រប់គ្រងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតាមរាជធានី-ខេត្ត លើការងារពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន

- បានបន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនថ្នាក់ស្រុក ក្រុង ឃុំ សង្កាត់ ។

# III. ការសន្និដ្ឋាន និងវាយតម្លៃ

**១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ក្នុងឆ្នាំ២០១៦នេះ យើងបានបន្តយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម ដោយបានពង្រីកសកម្មភាពអប់រំតាមគ្រប់រូបភាព ពិសេសយើងបានចូលធ្វើសកម្មភាពផ្សព្វផ្សាយ អប់រំ ទៅដល់តំបន់គោលដៅងាយប្រឈម និងតំបន់ស្មុគ្រស្មាញជាច្រើនកន្លែង និងគ្របដណ្តប់លើក្រុមជនងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ជាច្រើននាក់ ពិសេសនៅរាជធានីភ្នំពេញ ។ ជាមួយនេះយើងក៏បានចលនាកៀរគរ និងសហការជាមួយវិស័យឯកជនមួយចំនួន ដូចជា ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គការមិនមែនរដ្ឋាភិបាល ដែលពីមុនមិនធ្លាប់បានចូលរួម ឱ្យចូលរួមធ្វើការផ្សព្វផ្សាយ និងផលិតសម្ភារ ផ្សព្វផ្សាយ អប់រំផងដែរ ។

**ចំណុចខ្វះខាតគឺ ៖**

- អ្នកប្រើប្រាស់គ្រឿងញៀន នៅតែមានការកើនឡើង និងរាលដាលទៅដល់ទីជនបទមួយចំនួន

- ក្រុមគោលដៅប្រឈមពិតប្រាកដ និងក្រុមដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ភាគច្រើននៅតែភ័យខ្លាច និងគេចវេសពីការអប់រំ ជាហេតុធ្វើឱ្យការអប់រំមិនទទួលបានប្រសិទ្ធភាព

- ខ្លឹមសារនៃសារអប់រំអាចនៅមិនទាន់មានភាពទាក់ទាញចំពោះមហាជនទូទៅ ឬអាចទៅមិនដល់ក្រុមជនគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់

- ការបិទសារលើផលិតផលនានា នៅពុំទាន់បានទូលំទូលាយ និងឱ្យបានគ្រប់ផលិតផលនៅឡើយ ដើម្បីក្រើនរំលឹកពីគ្រោះថ្នាក់នៃគ្រឿងញៀន

- កម្មវិធីនិងសកម្មភាពផ្សេងទៀតរបស់ក្រសួង-ស្ថាប័នជាសមាជិក ដែលអាចធ្វើឱ្យមានការស្វែងយល់ពីបញ្ហាគ្រឿងញៀន នៅពុំទាន់អនុវត្តបានសកម្ម តាមគ្រប់រូបភាព និងលទ្ធភាពដែលខ្លួនមាន ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖** ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ-ឯកជន ក៏ដូចជាការព្យាបាលដោយផ្អែកលើសហគមន៍នៅតាមមូលដ្ឋានសុខាភិបាល មានការរីកចម្រើនជាងមុន អាស្រ័យដោយគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទាបានពង្រឹងយន្តការការងាររបស់ខ្លួន ។ ជាមួយនេះ អ្នកប្រើគ្រឿងញៀនក៏មានការភ្ញាក់រលឹកទៅទទួលសេវាព្យាបាលច្រើនជាងមុន ។

**ចំណុចខ្វះខាតគឺ ៖**

- អ្នកញៀនប្រមាណជាង ៤៥% ទៀត នៅមិនទាន់បានទៅទទួលសេវាព្យាបាល ដែលបញ្ហានេះអាចបណ្តាលមកពីមានការខ្លាចរអារ ព្រោះគិតថាខ្លួនបានប្រព្រឹត្តខុសនឹងច្បាប់ ឬមិនទាន់ទទួលបានព័ត៌មាន ឬមិនទាន់មានជំនឿលើសេវាព្យាបាល និងស្តារនីតិសម្បទា

- ភាពទាក់ទាញនៃការអប់រំ ការភ្ញាក់រលឹក ប្រសិទ្ធភាព និងគុណភាព នៃកម្មវិធីព្យាបាល ស្តារនីតិសម្បទាអាចពុំទាន់ឆ្លើយតបបានសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃជនរងគ្រោះ ។ ជាមួយនេះ យន្តការតាមដាន វាយតម្លៃ ក៏នៅមិនទាន់មានភាពច្បាស់លាស់ ដែលធ្វើឱ្យការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មនៅពុំទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ ពិសេសនៅមិនទាន់ទប់ស្កាត់បាននូវការលាប់ និងវិលទៅរកការប្រើប្រាស់គ្រឿងញៀនឡើងវិញ

- ក្នុងដំណាក់កាលនៃការបណ្តុះបណ្តាលបំណិនជីវិត និងវិជ្ជាជីវៈផ្សេងៗ នៅពុំទាន់ឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មនៅឡើយ

- កិច្ចពិភាក្សាជាមួយស្ថាប័នតុលាការ អយ្យការ ពាក់ព័ន្ធនឹងអ្នកប្រើប្រាស់និងអ្នកញៀនគ្រឿងញៀន ការចោទប្រកាន់ ឱ្យទៅទទួលយកសេវាព្យាបាល នៅពុំទាន់រៀបចំវិធានការរដ្ឋបាលឱ្យបានច្បាស់លាស់នៅឡើយ

- កម្មវិធីព្យាបាលពិរុទ្ធជន-ទណ្ឌិតដែលញៀនគ្រឿងញៀននៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ នៅមិនទាន់ដំណើរការនៅឡើយ

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ជារួម មន្ត្រីអនុវត្តន៍ច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទទួលបាននូវការបណ្តុះបណ្តាលជាបន្តបន្ទាប់ ធ្វើឱ្យកាន់តែមានសមត្ថភាពខ្ពស់ក្នុងការស្រាវជ្រាវស៊ើបអង្កេតបទល្មើស គួបផ្សំនឹងឆ្លងកាត់បទពិសោធន៍ច្រើន ការយល់ដឹងកាន់តែច្បាស់ពីល្បិចកលរបស់ក្រុមឧក្រិដ្ឋជនរួមជាមួយការប្រើប្រាស់កម្លាំងសរុប និងកិច្ចសហការក្នុងការផ្តល់ព័ត៌មានហ័សឱ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាងបានល្អ ធ្វើឱ្យការទប់ស្កាត់និងបង្ក្រាបបទល្មើសបានច្រើនករណីធំៗ ។ ទន្ទឹមនេះ កិច្ចសហការរវាងស្ថាប័នតុលាការ អយ្យការ ជាមួយស្ថាប័នអនុវត្តន៍ច្បាប់កាន់តែមានភាពរលូន ធ្វើឱ្យការជម្រះក្តីបទល្មើសគ្រឿងញៀនមិនអូសបន្លាយពេលវេលា ។

**បញ្ហាប្រឈមគឺ ៖**

- បណ្តាខេត្តនៅភាគឦសានប្រទេស នៅតែជាខេត្តដែលបន្តមានការហូរចូលគ្រឿងញៀនដោយខុសច្បាប់ ទោះបីយើងបង្ក្រាបបានចំករណីធំៗ និងកាត់ផ្តាច់ខ្សែរយៈទាក់ទងជាច្រើនហើយក៏ដោយ

- ក្រុមឧក្រិដ្ឋជនអន្តរជាតិ នៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់កម្ពុជា ធ្វើជាប្រទេសផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់ ។

**ចំណុចខ្វះខាតគឺ ៖**

- គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ មិនទាន់បានបំពេញតួនាទីភារកិច្ច របស់ខ្លួនឱ្យបានសកម្ម ហើយថែមទាំងមានការប្រែប្រួលសមាសភាពទៀតផង

- ការបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ពាក់ព័ន្ធនឹងច្បាប់នានា, ជំនាញប្រតិបត្តិការបង្ក្រាបបទល្មើស, នីតិវិធីក្នុងការកសាងសំណុំរឿង យើងធ្វើបានច្រើន ប៉ុន្តែក្រុមមន្ត្រីអនុវត្តន៍ច្បាប់ជាជនបង្គោលនៅតាមខេត្ត យើងបណ្តុះបណ្តាលបានតិច ធ្វើឱ្យការងារនេះមិនបានជួយដោះបន្ទុកដល់គ្រូបង្គោលរបស់ថ្នាក់កណ្តាល និងថ្នាក់ជាតិ ។

- មន្ត្រីអនុវត្តន៍ច្បាប់មួយចំនួនតូចនៅមូលដ្ឋាន ខ្វះការទទួលខុសត្រូវក្នុងការបង្ក្រាបបទល្មើសដែលកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន, ខ្លះទៀតមិនត្រឹមតែមិនគោរព និងលើកកម្ពស់ក្រមសីលធម៌ វិជ្ជាជីវៈរបស់ខ្លួន តែថែមទាំងមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនទៀតផង

- ម្ចាស់ទីតាំងផ្ទះសំណាក់ ផ្ទះជួល អាជីវកម្ម សេវាកម្មកម្សាន្តមួយចំនួន នៅក្នុងភូមិសាស្ត្រងាយកើតមានបទល្មើស (ជាពិសេសនៅរាជធានីភ្នំពេញ) មិនត្រឹមតែមិនផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនដល់សមត្ថកិច្ចប៉ុណ្ណោះទេ តែថែមទាំងឆ្លៀតឱកាសនេះ ឃុបឃិតទាញយកផលប្រយោជន៍ពីជនល្មើស ពីអ្នកប្រើប្រាស់ តាមរយៈការលក់ឧបករណ៍ប្រើប្រាស់គ្រឿងញៀន ឬជួលបន្ទប់ ជួលទីតាំង ឬទទួលធ្វើយានជំនិះ ជាដើម

- បញ្ហាថវិកា មធ្យោបាយ សម្ភារ សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតែជាបញ្ហាចោទចំពោះមុខដែលត្រូវដោះស្រាយ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលមានការអនុញ្ញាតឱ្យនាំចូល ។ តាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់យើងកាន់តែមានបទពិសោធន៍ និងចេះសង្ស័យពីសារធាតុគីមីផ្សំមួយចំនួន ព្រមទាំងបង្ការ ទប់ស្កាត់បានការបង្វែរយកទៅសំយោគផលិតជាគ្រឿងញៀន ។

*ចំណុចខ្វះខាតគឺ ៖*

*- យន្តការរបស់ក្រុមការងារអន្តរក្រសួងដែលបានបង្កើតហើយ នៅមិនទាន់បានបំពេញការងាររបស់ខ្លួនឱ្យបានសកម្ម ហើយថែមទាំងមានការប្រែប្រួលសមាសភាពថែមទៀតផង ដែលយើងមិនទាន់បានធ្វើការកែសម្រួលនៅឡើយ*

*- ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមិនទាន់ធ្វើបានទូលំទូលាយនៅឡើយ*

*- នៅមិនទាន់មានការត្រួតពិនិត្យបានច្បាស់លាស់ពីការចរាចរ ការប្រើប្រាស់ និងសន្និធិសារធាតុគីមីផ្សំដែលប្រើប្រាស់ដោយសិប្បកម្មក្នុងស្រុកនានា ។*

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** ជារួមយើងបាននិងកំពុងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ត្រីភាគីតាមរយៈយន្តការដែលមានស្រាប់បានល្អប្រសើរគួរឱ្យកត់សម្គាល់ ក្នុងនោះ យើងបានធ្វើការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ដែលអាចឈានទៅដល់ការបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែន ទទួលបានលទ្ធផលគួរកត់សម្គាល់ ។ ជាមួយនេះ យើងក៏បានទទួលនូវការគាំទ្រមួយចំនួនទាំងការបណ្តុះបណ្តាលជំនាញ និងសម្ភារពីភាគីមិត្តផងដែរ ។

**ចំណុចខ្វះខាតគឺ ៖**

- មិនទាន់អនុវត្តបាននូវខ្លឹមសារក្នុងការកសាងភូមិ-ឃុំ សហគមន៍គ្មានគ្រឿងញៀន នៅតាមព្រំដែន

- យន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) រវាងប្រទេសកម្ពុជា ជាមួយប្រទេសថៃ ឡាវ និងវៀតណាម នៅមិនទាន់ត្រូវបានពង្រឹងឱ្យបានរឹងមាំ

- គម្រោងដែលជាតម្រូវការចាំបាច់សម្រាប់កម្ពុជាមួយចំនួន ទើបតែនឹងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០១៧ ដូចជា គម្រោងមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ ឡាវ ជាដើម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** យើងនៅតែបន្តចូលរួមគាំទ្រ និងសហការយ៉ាងសកម្មនូវគ្រប់យន្តការទាំងក្នុងកម្រិតអនុតំបន់ តំបន់ និងអន្តរជាតិ ។ ប៉ុន្តែទោះបីយ៉ាងណាកិច្ចសហប្រតិបត្តិការរបស់យើងក្នុងរយៈពេលចុងក្រោយនេះ ភាគច្រើន គឺទទួលបាននូវការគាំទ្រជាស្មារតី និងការបណ្តុះបណ្តាលជំនាញ ។ ដោយឡែក ការគាំទ្រជា ថវិកា និងមធ្យោបាយ សម្ភារ ដែលជាតម្រូវការចាំបាច់របស់យើងក្នុងការឆ្លើយតបទៅនឹងស្ថានភាពគ្រឿងញៀនជាក់ស្តែងគឺមានកម្រិតតិចតួចបំផុត ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ជារួម នៅថ្នាក់ជាតិ យើងមានយន្តការត្រួតពិនិត្យគ្រឿងញៀនពហុវិស័យ សម្រាប់ចង្អុលដឹកនាំ ណែនាំទៅថ្នាក់ខេត្ត ។

**ចំណុចខ្វះខាតគឺ ៖**

- បន្ទាប់ពីការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទើបយើងរកឃើញផលអវិជ្ជមានមួយចំនួនរបស់រាជធានី-ខេត្ត ដូចជា យន្តការការងារត្រួតពិនិត្យគ្រឿងញៀនភាគច្រើនផ្តោតតែលើការងារបង្ក្រាបបទល្មើសគ្រឿងញៀនតែមួយមុខ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន មាននៅតែនៅថ្នាក់រាជធានី-ខេត្ត ឯនៅសង្កាត់ ឃុំ រហូតមកដល់ពេលនេះនៅមិនទាន់បានបង្កើតអស់នៅឡើយ

- ក្នុងអង្គភាពទ័ព ទាំងនៅជួរមុខ ក៏ដូចជានៅជួរក្រោយ នៅមិនទៅមានយន្តការការងារត្រួតពិនិត្យគ្រឿងញៀននៅឡើយ

- មាត្រាមួយចំនួនដែលបានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលនៃបទល្មើសគ្រឿងញៀន) គឺមិនឱ្យអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិគ្រប់គ្រង ចាត់ចែង លក់ដូរបានភ្លាមៗ នូវទ្រព្យសម្បត្តិ មុនពេលដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរ ដែលជាហេតុធ្វើឱ្យទ្រព្យសម្បត្តិនោះត្រូវបាត់បង់ ឬខូចគុណភាពនៅពេលដំណើរការក្តីចប់ ហេតុនេះហើយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនពុំមានលទ្ធភាពផ្តល់ជាថវិកាលើកទឹកចិត្តជូនដល់អង្គភាពអនុវត្តច្បាប់ និងសម្រាប់ប្រើប្រាស់បម្រើសកម្មភាពត្រួតពិនិត្យគ្រឿងញៀនបានទេ

- លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបម្រើដល់ការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅមិនទាន់កសាងបានគ្រប់គ្រាន់នៅឡើយ

- អង្គភាពទទួលខុសត្រូវលើកិច្ចការគ្រឿងញៀនរបស់ក្រសួង-ស្ថាប័នសមាជិក អ.ជ.ប.គ.ញ. អនុវត្តកិច្ចការពាក់ព័ន្ធនឹងគ្រឿងញៀនបានច្រើន ប៉ុន្តែមិនបានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់ខ្លួន។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៧

ផ្អែកលើការសន្និដ្ឋាន និងវាយតំលៃខាងលើ រួមជាមួយនឹងការបន្តអនុវត្តផែនការជាតិ៣ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១៦-២០១៨) ការអនុវត្តបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅសម្រាប់ ឆ្នាំ២០១៧ ដូចខាងក្រោម ៖

១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

- រៀបចំធ្វើបច្ចុប្បន្នភាពលើ ខ្លឹមសារនៃឯកសារអប់រំផ្សព្វផ្សាយ សម្រាប់លើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន ឱ្យមានភាពទាក់ទាញចំចិត្តសាស្ត្រអ្នកញៀនគ្រឿងញៀន ចាត់តាំងអនុវត្តសកម្មភាពនេះ ឱ្យបានជាប់ជាប្រចាំ តាមគ្រប់រូបភាព ប្រើប្រាស់ឱ្យអស់លទ្ធភាពដែលមាន និងឱ្យចំគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ។

- ជំរុញការអប់រំផ្សព្វផ្សាយ តាមគ្រប់រូបភាពជាប្រចាំ និងចំគោលដៅប្រឈមពិតប្រាកដរួមមានទីតាំងអាជីវកម្ម សេវាកម្មទេសចរណ៍ គ្រឹះស្ថានអប់រំ រោងចក្រ សហគ្រាស វេទិកាសាធារណៈ កម្មវិធីសាសនា វេទិកាតុមូល ចាក់ផ្សាយតាមវិទ្យុ ទូរទស្សន៍ ប្រព័ន្ធទំនាក់ទំនងព័ត៌មានសង្គម និងក្រុមដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ជាពិសេស សិស្សគេចសាលា ក្មេងទំនើងដែលមានតម្រុយប្រើប្រាស់គ្រឿងញៀន អ្នកបើកបររថយន្តដឹកជញ្ជូន ព្រមទាំងបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមមូលដ្ឋាន ។ល។

- បន្តរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់ឆ្នាំ២០១៧

- បង្កើនការចលនា លើកទឹកចិត្តដល់អាណាព្យាបាល ក៏ដូចជាវិស័យឯកជន ក្នុងការចូលរួមលើការងារអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន រួមទាំងបង្កើនការបិទសារអប់រំលើផលិតផលនានា

- ចងក្រងយន្តការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងការអប់រំសីលធម៌បដិសេធគ្រឿងញៀន នៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត និងមជ្ឈមណ្ឌលសហគមន៍

- ជំរុញនិងលើកទឹកចិត្តគ្រូបង្រៀន សិស្ស និស្សិត និងគរុសិស្សចូលរួមបង្ការ ទប់ស្កាត់ និងលុបបំបាត់គ្រឿងញៀននៅក្នុងសង្គម ដោយធ្វើការអភិវឌ្ឍសៀវភៅសិក្សាគោលស្តីពីការអប់រំនូវខ្លឹមសារអប់រំ បង្ការគ្រឿងញៀន តាមរូបភាពសិល្បៈអប់រំ ដូចជាគូរគំនូរ តែងចម្រៀង តែងកំណាព្យ លេងកីឡា និងសិល្បៈ ពិសេសពង្រឹកសមត្ថភាពផ្សព្វផ្សាយ អប់រំ ដល់សិស្សបោះបង់ការសិក្សា និងមករៀនមិនទៀងទាត់

- លើកទឹកចិត្តដល់អតីតអ្នកញៀនគ្រឿងញៀន និងក្រុមគ្រួសារដែលបានចាកចេញពីគ្រឿងញៀន ដើម្បីឱ្យពួកគេចូលរួមក្នុងការអប់រំមហាជនឱ្យចេះបដិសេធគ្រឿងញៀន

- ចលនាឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា វិស័យឯកជន សំដៅកាត់បន្ថយតម្រូវការគ្រឿងញៀន តាមគ្រប់រូបភាព គ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖

- ពង្រឹងគុណភាព និងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- ពង្រឹងគុណភាព សមត្ថភាព និងជំនឿចិត្តលើកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ដោយមានយន្តការដាក់លាក់តាមខ្លឹមសារបីគឺ ៖ ការព្យាបាល, ការបណ្តុះបណ្តាលវិជ្ជាជីវៈ, ការធ្វើសមាហរណកម្ម ព្រមទាំងជំរុញការអនុវត្តនូវវិធានការគាំទ្រលើកទឹកចិត្ត វិធានការរដ្ឋបាល និងវិធានការច្បាប់

- ចលនាឱ្យមានការចូលរួមពីគ្រប់បុគ្គល និងអង្គភាព តាមរយៈការបំផុស និងលើកទឹកចិត្តដល់អ្នកញៀនគ្រឿងញៀនឱ្យមកទទួលយកសេវាព្យាបាលនៅតាមសេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន របស់ក្រសួងសុខាភិបាល

- ត្រូវធ្វើការពន្យល់ដល់គ្រប់តួអង្គដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ដូចជាក្រុម គ្រួសារ អាណាព្យាបាល ពិសេសសាមីខ្លួនជាអ្នកញៀន ឱ្យយល់ច្បាស់ថាវិធីសាស្ត្រដែលល្អ និងមានប្រសិទ្ធភាពបំផុត គឺការបន្សាបព្យាបាលដោយផ្ទាល់នៅតាមសហគមន៍ ។

- រៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំស្ទឹងហាវ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

- រៀបចំបង្កើតមជ្ឈមណ្ឌលបណ្តោះអាសន្នសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅកងពលតូចអន្តរាគមន៍លេខ ១១ ក្នុងស្រុកជុំគិរី ខេត្តកំពត ។

- ខេត្តដែលមានអ្នកញៀនគ្រឿងញៀនច្រើន ត្រូវពិនិត្យលទ្ធភាពរៀបចំបង្កើតមណ្ឌលសង្គមកិច្ចសម្រាប់ជួយដោះស្រាយបញ្ហាអ្នកញៀនគ្រឿងញៀននៅក្នុងខេត្តរបស់ខ្លួន

- ចាត់វិធានការបន្តថែទាំសុខភាពអ្នកដែលបានចាកចេញពីគ្រឿងញៀន ព្រមទាំងបន្តពង្រឹងកិច្ចសហការរវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការជាដៃគូ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន និងមេរោគអេដស៍ ជំងឺអេដស៍

- ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអនុវត្តតាមតួនាទី ភារកិច្ច បន្សាប ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មចំពោះអ្នកចាកចេញពីគ្រឿងញៀនទៅកាន់គ្រួសារ និងសហគមន៍វិញ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖**

- ចាត់វិធានការគ្រប់បែបយ៉ាងតាមផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីប្រឆាំងការផលិត ការដាំដុះ ការចម្រាញ់ ការចរាចរជួញដូរ ការស្តុកទុក ការប្រើប្រាស់គ្រឿងញៀន រួមទាំងទីតាំងសម្រួលឱ្យប្រើប្រាស់ តាមគ្រប់រូបភាព

- លើកកម្ពស់គុណភាពនៃការអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំង និងឧបាយកលថ្មីៗរបស់ឧក្រិដ្ឋជនគ្រឿងញៀន ដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង និងអន្តរជាតិ ទប់ស្កាត់ការហូរចូលឱ្យបានជាអតិបរមានូវគ្រឿងញៀនគ្រប់ប្រភេទឆ្លងកាត់ព្រំដែន ជាពិសេសព្រំដែនកម្ពុជា-ឡាវ និងបន្តដំឡើងផែនទីគោលដៅដែលត្រូវចាត់វិធានការក្តៅបោសសម្អាតសកម្មភាពប្រព្រឹត្តបទល្មើសគ្រឿងញៀន ក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តពិសេសបន្តតាមដានកិច្ចប្រតិបត្តិការនៅគោលដៅតំបន់ត្រពាំងឈូក និងកន្លែងផ្សេងៗទៀត នៅរាជធានីភ្នំពេញ

- ពង្រឹងការយល់ដឹង សមត្ថភាព ឆន្ទៈ គុណធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវនៃស្ថាប័នអនុវត្តន៍ច្បាប់សំដៅបង្កើនគុណភាពនិងកាត់បន្ថយភាពអសកម្មនានា ដែលជាការមិនស្មោះត្រង់ចំពោះវិជ្ជាជីវៈ និងការទទួលខុសត្រូវ

- ពង្រឹងយន្តការចូលរួមនិងលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ក្នុងការកសាងសំណុំរឿង ដើម្បីដាក់ទោសជនល្មើសឱ្យបានត្រឹមត្រូវថែមទៀត ស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពិសេសការអនុវត្តមាត្រា ៧៤ និងការកែទម្រង់ប្រព័ន្ធតុលាការ តាមរយៈច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា, ច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- ជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់តំបន់គោលដៅងាយកើតមានបញ្ហាគ្រឿងញៀន ដូចជា ផ្ទះសំណាក់ ផ្ទះជួល សណ្ឋាគារ មណ្ឌលកម្សាន្តនានា ជាដើម និងបន្តបំផុសលើកទឹកចិត្តដល់ម្ចាស់

ទីតាំងទាំងនោះឱ្យភ្ញាក់រលឹក និងសហការឱ្យបានសកម្ម ដើម្បីបង្ការទប់ស្កាត់បទល្មើសគ្រឿងញៀន ជាមួយស្ថាប័នមានសមត្ថកិច្ចអាជ្ញាធរមូលដ្ឋានដើម្បីជៀសវាងការពិន័យតាមវិធានការរដ្ឋបាល

- បន្តកិច្ចសហការជាមួយធនាគារអភិវឌ្ឍន៍ពិភពលោក ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រពង្រឹងប្រសិទ្ធភាពប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

- រៀបចំអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន

- កែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ និងក្រុមលេខាការងារនេះ

- បង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំដែលនាំចូលស្របច្បាប់ និងមិនស្របច្បាប់ ព្រមទាំងវត្ថុធាតុដើម ឬសារធាតុផ្សំមួយចំនួនទៀត

- បង្ការ ទប់ស្កាត់ ការបង្វែរសារធាតុគីមីផ្សំ យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ ដល់មន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ និងបុគ្គលិករោងចក្រ សហគ្រាស ក្រុមហ៊ុន និងឧស្សាហកម្មដែលប្រើប្រាស់សារធាតុគីមី ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

- លើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង តាមគ្រប់រូបភាព ដោយផ្តោតសំខាន់លើការទប់ស្កាត់ការចរាចរគ្រឿងញៀន តាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងតាមបញ្ញើប្រៃសណីយ៍

- បន្តពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រដែន (BLO) កម្ពុជា-ឡាវ-ថៃ និងវៀតណាម

- រៀបចំអនុវត្តគម្រោងមេគង្គក្រោម សម្រាប់ប្រទេសកម្ពុជា ថៃ និង ឡាវ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

- បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពង្រឹងនិងពង្រីកកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន

- បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីស្វែងរកមូលនិធិគាំទ្រលើការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

- កៀរគរបណ្តាប្រទេសផ្តល់ជំនួយនិងដៃគូអភិវឌ្ឍន៍នានា ពិសេសអង្គការ UNODC ដើម្បីគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា តាមរយៈការអនុវត្តផែនការសកម្មភាពរបស់បណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ

- ចូលរួមគ្រប់វេទិកាទាំងក្នុងតំបន់និងអន្តរជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការចរាចរ ជួញដូរគ្រឿងញៀន

- បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-កូរ៉េ សំដៅពង្រឹង សមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន និងគាំទ្រដល់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

- ត្រៀមចូលរួមអនុវត្តផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់រាជរដ្ឋាភិបាល

- បន្តដឹកនាំការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- រៀបចំអនុវត្តទិសដៅ ០៨ ចំណុច ដែលសម្តេចតេជោ បានឯកភាពកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦

- ពង្រឹងស្ថាប័នសេនាធិការ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពង្រីកលទ្ធភាពអនុវត្តវិធានការយុទ្ធសាស្ត្រពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យមានប្រសិទ្ធភាព

- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលយុត្តិធម៌ថ្នាក់ក្រោមជាតិនៅតាមបណ្តាខេត្តគោលដៅមួយចំនួន ។

៨. ជំរុញការអនុវត្តអនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៩. អនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមាន ស្នាដៃលើការងារផ្សព្វផ្សាយអប់រំ ស្នាដៃការព្យាបាលនិងស្តារនីតិសម្បទា ស្នាដៃក្នុងការអនុវត្តច្បាប់ លើកទឹកចិត្តចំពោះអតីតអ្នកញៀនគ្រឿងញៀន ក្រុមគ្រួសារ និងសហគមន៍របស់គេ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែណែនាំ និងតម្រង់ទិសលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយឧបត្ថម្ភ គាំពារលើការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ។

សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ផ្នែកសាសនា បុគ្គលពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន ប្រជាពលរដ្ឋ ដែលបានចូលរួមចំណែកជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការធ្វើឱ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានក្នុងរបាយការណ៍ខាងលើ ។

សូមអំពាវនាវដល់គ្រប់សមាសភាពពាក់ព័ន្ធទាំងអស់ បន្តការគាំទ្រដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីអនុវត្តកម្មវិធីការងារឱ្យកាន់តែទទួលបានលទ្ធផលជោគជ័យថ្មីៗបន្ថែមទៀត តាមទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញសម្រាប់អនុវត្តនៅក្នុងឆ្នាំ២០១៧ ខាងមុខនេះ ។

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**នាយឧត្តមសេនីយ៍.កែ_គីមយ៉ាន**

**ចម្លងជូន** :
ឧទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
" ដើម្បីជូនជ្រាប "
-ក្រសួងសមាជិក អ.ជ.ប.គ.ញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ